CITY OF SALISBURY

# New Resident Handbook

*Welcome to Salisbury*

**KHMER**

CITY OF
Salisbury

## ព័ត៌មានសម្រាប់ទាក់ទងនៅគ្រាមានអាសន្ន និងការទាក់ទងជាមួយសាលាក្រុង

### ការទាក់ទងនៅគ្រាមានអាសន្ន

| | |
|---|---|
| **គ្រាមានអាសន្ន – ឡានពេទ្យ ប៉ូលិស អគ្គីភ័យ** | 000 |
| **ក្រសួងប៉ូលិស** (ពុំមែនសម្រាប់គ្រាមានអាសន្នឡើយ) | 13 14 44 |
| **ទូរស័ព្ទជំនួយសម្រាប់ការមើលថែពេលមានវិបត្តិ**<br>សេវាតាមទូរស័ព្ទដោយឥតគិតថ្លៃសម្រាប់ផ្តល់ព័ត៌មាន និងឱវាទចំពោះអ្នកត្រូវការជំនួយ | 13 16 11 |
| **ទូរស័ព្ទជួយសង្គ្រោះជីវិត** (Lifeline)<br>កិច្ចបំរើតាមទូរស័ព្ទដោយឥតគិតថ្លៃសម្រាប់ផ្តល់ព័ត៌មាន និងឱវាទចំពោះអ្នកត្រូវការជំនួយ | 13 11 14 |
| **គ្រាមានអាសន្នផ្នែកថាមពលអគ្គីសនី** (២៤ម៉ោង) | 13 13 66 |
| **គ្រាមានអាសន្នផ្នែកឧស្ម័ន** (២៤ម៉ោង) | 1800 808 526 |
| **សេវាផ្តល់ព័ត៌មានអំពីថ្នាំពុល** | 13 11 26 |
| **គ្រាមានអាសន្នផ្នែកទឹក / លូបង្ហូរកាកសំណល់** (២៤ម៉ោង) | 1300 883 121 |
| **សេវាព្យាបាលធ្មេញ រដ្ឋអូស្ត្រាលីខាងត្បូង** (SA Dental Service) (គ្រាមានអាសន្នក្រោយពេលម៉ោងធ្វើការ) | 8232 1034 |
| Health Direct Australia **(សេចក្តីណែនាំផ្នែកសុខភាពអូស្ត្រាលី)**<br>សម្រាប់ឱវាទដោយឥតគិតថ្លៃ ប្រសិនបើលោកអ្នកដឹងខ្លួនថាឈឺ ហើយពុំដឹងច្បាស់ថាត្រូវធ្វើអ្វីខ្លះ | 1800 022 222 |

### ការទាក់ទងជាមួយសាលាក្រុង

យើងចង់ធ្វើឲ្យងាយស្រួលសម្រាប់លោកអ្នកនិយាយជាមួយយើង។ ពេលម៉ោងធ្វើការនៅការិយាល័យរបស់យើងគឺ**៨.៣០**ព្រឹក - ៥.០០ល្ងាច ថ្ងៃច័ន្ទ ទៅដល់ថ្ងៃសុក្រ លើកលែងតែថ្ងៃឈប់សម្រាកសាធារណៈ។

| | |
|---|---|
| មជ្ឈមណ្ឌលអតិថិជន | 8406 8222 |
| TTY (សម្រាប់អ្នកមានពិការភាពខាងការស្តាប់) | 8406 8596 |
| សម្រាប់សេវាសាលាក្រុងក្រោយពេលម៉ោងធ្វើការ | 8406 8222 |

វិបសាយ: www.salisbury.sa.gov.au

អ៊ីម៉េល: city@salisbury.sa.gov.au

## សូមស្វាគមន៍ដែលបានអញ្ជើញមកក្រុង Salisbury!

**យើងមានសេចក្តីរីករាយសូមស្វាគមន៍លោកអ្នកជាអ្នកពលរដ្ឋរស់នៅក្នុងតំបន់ថ្មី។ ក្រុង Salisbury មានទីតាំងនៅចម្ងាយ២៥ គ.ម ខាងជើងទីក្រុងអាដឺឡែត។ វាគ្របដណ្តប់លើផ្ទៃដី១៦១គីឡូម៉ែត្រក្រឡា លាតសន្ធឹងពីច្រាំងសមុទ្រ Gulf St Vincent ទៅដល់ Para Escarpment និងជើងខ្ពង់រាបនៃជងភ្នំ Mt Lofty Ranges មានរួមបញ្ចូលតំបន់ជាយក្រុងចំនួន៣២ និងជាទីលំនៅសម្រាប់ពលរដ្ឋរស់ក្នុងតំបន់ប្រមាណជា ១៣០០០០នាក់។**

ក្រុងរបស់យើងត្រូវបានទទួលស្គាល់ថាជាអ្នកនាំមុខជាតិផ្នែកឧស្សាហកម្មផ្សេងៗមួយចំនួនមានរួមទាំងផ្នែកការពារ អេឡិចត្រូនិច និងបច្ចេកវិទ្យា ព្រមទាំងមជ្ឈមណ្ឌលសម្រាប់សកម្មភាពផលិត ការចែកចាយ និងការផ្ទុកឥវ៉ាន់ក្នុងឃ្លាំងផងដែរ។ មានឧទ្យានដ៏ល្អស្អាត តំបន់បំរុងទុក និងតំបន់ទំនាបវាលភក់ល្បីជាច្រើន សម្រាប់ពលរដ្ឋរស់នៅក្នុងតំបន់ និងអ្នកមកលេងដើម្បីរុករក និងសប្បាយរីករាយ។ ក្រុង Salisbury មានទីកន្លែងជាង៥០ដែលបានសាងសង់ឡើងក្នុងគោលបំណងសម្រាប់មជ្ឈមណ្ឌលកំសាន្ត និងក្លឹប ទីផ្សារធំៗ មជ្ឈមណ្ឌលសហគមន៍ បណ្ណាល័យ រោងភាពយន្តធំៗ និងភោជនីយដ្ឋាន និងសណ្ឋាគារធំៗជាច្រើនទៀត។

សាលាក្រុងផ្តល់សេវា និងកម្មវិធីសម្រាប់សហគមន៍ផ្សេងៗរបស់យើង ដោយមានរួមទាំងកម្មវិធីផ្នែកវប្បធម៌សម្រាប់ពលរដ្ឋរស់នៅក្នុងតំបន់ដែលមានវ័យចាស់ ថ្នាក់រៀនភាសា និងការរៀនអាន និងសរសេរ និងឱកាសសម្រាប់ការស្ម័គ្រចិត្ត។ បន្ថែមពីលើនេះ សេវាបណ្ណាល័យ Salisbury មានសម្ភារៈជាភាសាអារ៉ាប់ ចិន អ៊ីតាលី ហុលឡង់ ខ្មែរ អាល្លឺម៉ង់ ប៉ូឡូញ ក្រិច អេស្ប៉ាញ ហ៊ីនឌី និងភាសាវៀតណាម។

## មជ្ឈមណ្ឌលសហគមន៍

**មជ្ឈមណ្ឌលសហគមន៍របស់យើងគឺជាកន្លែងផ្សេងៗគ្នា និងពោរពេញដោយសកម្មភាពរស់រវើក ហើយមជ្ឈមណ្ឌលនីមួយៗមានផ្តល់កម្មវិធីផ្សេងៗគ្នាមួយចំនួនសម្រាប់ពលរដ្ឋរស់នៅក្នុងតំបន់។ កម្មវិធីប្រែប្រួលពីមជ្ឈមណ្ឌល ទៅមជ្ឈមណ្ឌល និងផ្លាស់ប្តូរក្នុងឆមាសនីមួយៗ ក៏ប៉ុន្តែអាចមានរួមទាំង:**

- ការបង្រៀនប្រើឧបករណ៍ និងបច្ចេកវិទ្យា
- ការសរសេរសេចក្តីសង្ខេបនៃបទពិសោធន៍ការងារ និងជំបូន្មានសម្រាប់ស្វែងរកការងារ
- ការហ្វឹកហ្វឺនភាសា និងការចេះអាន និងចេះសរសេរ
- ថ្នាក់រៀនចំអិនម្ហូបអាហារ
- កម្មវិធីហាត់ប្រាណដើម្បីឲ្យរាងកាយមាំមួន
- សកម្មភាពប៉ិនប្រសប់ និងការកំសាន្ត
- ក្រុមកុមារតូចៗលេងជាមួយគ្នា
- ក្រុមផ្គត់ផ្គង់គ្រួសារ
- វគ្គផ្តល់ព័ត៌មានផ្នែកសុខភាព

**សូមអញ្ជើញមកមជ្ឈមណ្ឌលណាមួយនៃមជ្ឈមណ្ឌលទាំងឡាយរបស់យើង ដើម្បីស្វែងយល់ឲ្យបានច្រើនថែមទៀត!**

### ទីតាំងមជ្ឈមណ្ឌលសហគមន៍

| មជ្ឈមណ្ឌលសហគមន៍ | ទូរស័ព្ទ | ទីតាំង |
|---|---|---|
| មជ្ឈមណ្ឌលសហគមន៍ Bagster Road | 8250 4167 | 17 Bagster Road, Salisbury North |
| មជ្ឈមណ្ឌលសហគមន៍ Burton | 8280 8843 | 386 Waterloo Corner Road, Burton |
| មជ្ឈមណ្ឌលសហគមន៍ Morella | 8250 7786 | 90 Kings Road, Parafield Gardens |
| មជ្ឈមណ្ឌល Paddocks | 8258 8099 | Cnr Bridge and Kesters Roads, Para Hills West |
| មជ្ឈមណ្ឌលសហគមន៍ ចំការ Pooraka | 8262 5544 | 126 Henderson Avenue, Pooraka |
| មជ្ឈមណ្ឌលសង្កាត់ជិតខាង Salisbury ខាងកើត | 8285 2055 | 28 Smith Road, Salisbury |
| មជ្ឈមណ្ឌល Mawson | 8302 5449 | 2-8 Main Street, Mawson Lakes |
| មជ្ឈមណ្ឌលសហគ្រាសយុវជន Twelve25 Salisbury (១២-២៥ឆ្នាំ) | 8253 9928 | 17-19 Wiltshire Street, Salisbury SA 5108 |
| មជ្ឈមណ្ឌល Jack Young (អាយុលើសពី៥០ឆ្នាំ) | 8406 8525 | 1 Orange Avenue, Salisbury SA 5108 |
| មជ្ឈមណ្ឌល Para Hills (អាយុលើសពី៥០ឆ្នាំ) | 8395 1520 | Wilkinson Road, Para Hills SA 5096 |

## សេវាបណ្ណាល័យ

បណ្ណាល័យរបស់ក្រុង Salisbury គឺជាកន្លែងល្អសម្រាប់មនុស្សគ្រប់វ័យ និងគ្រប់សញ្ជាតិទាំងអស់ដើម្បីជួបជុំគ្នា អាន រៀនសូត្រ និងទទួលព័ត៌មាន។ ពលរដ្ឋរស់នៅក្នុងតំបន់អាចខ្ចីសៀវភៅ តន្ត្រី ឌីវីឌី ប្រដាប់ក្មេងលេង និងល្បែង។ លោកអ្នកអាចប្រើអ៊ីនធើណិតដោយឥតគិតថ្លៃ បោះពុម្ព និងស្កែន (scan) ឬចូលរួមក្នុងកម្មវិធីណាមួយនៃកម្មវិធីជាច្រើនទៀតរបស់បណ្ណាល័យ ដូចជាកម្មវិធីវិស្សមកាលសិក្សា ការអានរឿងឲ្យកូនក្មេងស្តាប់ និងក្លឹបអ្នកអានសៀវភៅជាដើម។

សមាជិកភាពគឺឥតគិតថ្លៃ ដែលអ្នកប្រើប្រាស់បណ្ណាល័យអាចខ្ចីវត្ថុពីបណ្ណាល័យសាធារណៈណាមួយគ្រប់ទីកន្លែងក្នុងរដ្ឋ។ ពលរដ្ឋរស់នៅក្នុងតំបន់ដែលមានការលំបាកផ្នែកដឹកជញ្ជូន ឬចល័តភាពអាចមានសិទ្ធិទទួលបានសម្ភារៈបណ្ណាល័យដែលយកទៅប្រគល់ជូនដល់ផ្ទះដោយសេវាបណ្ណាល័យជូនដល់ផ្ទះដោយឥតគិតថ្លៃ។ សូមទូរស័ព្ទលេខ 8406 8341 សម្រាប់ព័ត៌មានបន្ថែម។

បណ្ណាល័យរបស់ក្រុង Salisbury ក៏ផ្តល់ជូនសេវា Justice of the Peace (ចៅក្រមថ្នាក់ក្រោម) ដោយឥតគិតថ្លៃផងដែរ។ ចៅក្រមថ្នាក់ក្រោមត្រូវបានអនុញ្ញាតដើម្បីធ្វើជាសាក្សី និងប្រកាសថាពិតចំពោះឯកសារផ្លូវការទាំងឡាយ។ ពុំចាំបាច់ធ្វើការណាត់ជួបឡើយ។ ចំពោះពេលម៉ោង និងទីកន្លែង សូមទូរស័ព្ទលេខ 8406 8341។

website របស់យើងជាប្រភពព័ត៌មានដ៏សំខាន់អំពីសេវាបណ្ណាល័យ។ លោកអ្នកអាចរកឃើញកម្មវិធី និងព្រឹត្តិការណ៍ដែលនឹងកើតមានឡើងឆាប់ៗ ស្វែងរកវត្ថុក្នុងបញ្ជីរាយឈ្មោះសម្ភារៈតាមអ៊ីនធើណិតរបស់យើង និងច្រើនជាងនេះទៀត។

### ទីតាំងបណ្ណាល័យ និងពេលម៉ោងធ្វើការ

| សាខា | ពេលម៉ោងធ្វើការ | ទូរស័ព្ទ | ទីតាំង |
|---|---|---|---|
| បណ្ណាល័យ<br>Len Beadell | ថ្ងៃច័ន្ទ - ថ្ងៃពុធ និង ថ្ងៃសុក្រ ម៉ោង៩.៣០ព្រឹក - ម៉ោង៥.៣០ល្ងាច<br>ថ្ងៃព្រហស្បតិ៍ ម៉ោង៩.៣០ព្រឹក - ម៉ោង៨យប់<br>ថ្ងៃសៅរ៍ ម៉ោង៩.៣០ព្រឹក - ម៉ោង៣.៣០រសៀល<br>ថ្ងៃអាទិត្យ ម៉ោង១.៣០រសៀល - ម៉ោង៤.៣០រសៀល | 8406 8283 | 55 John Street, Salisbury |
| បណ្ណាល័យ<br>Mawson Lakes | ថ្ងៃច័ន្ទ និងថ្ងៃពុធ ម៉ោង៩.៣០ព្រឹក - ម៉ោង៥ល្ងាច<br>ថ្ងៃអង្គារ៍ និងថ្ងៃព្រហស្បតិ៍ ម៉ោង៩.៣០ព្រឹក - ម៉ោង៧យប់<br>ថ្ងៃសុក្រ ម៉ោង៩.៣០ព្រឹក - ម៉ោង៥ល្ងាច<br>ថ្ងៃសៅរ៍ ម៉ោង១០ព្រឹក - ម៉ោង៤.៣០រសៀល<br>ថ្ងៃអាទិត្យ ម៉ោង២រសៀល - ម៉ោង៥រសៀល | 8302 5555 | 2-8 Main Street, Mawson Lakes |
| បណ្ណាល័យ<br>Para Hills | ថ្ងៃច័ន្ទ - ថ្ងៃពុធ និង ថ្ងៃសុក្រ ម៉ោង៩.៣០ព្រឹក - ម៉ោង៥.៣០ល្ងាច<br>ថ្ងៃព្រហស្បតិ៍ ម៉ោង៩.៣០ព្រឹក - ម៉ោង៧យប់<br>ថ្ងៃសៅរ៍ ម៉ោង១០ព្រឹក - ម៉ោង១រសៀល<br>ថ្ងៃអាទិត្យបិទទ្វារ | 8264 2512 | Wilkinson Road, Para Hills |
| បណ្ណាល័យ<br>Salisbury West | ថ្ងៃច័ន្ទ - ថ្ងៃពុធ និង ថ្ងៃសុក្រ ម៉ោង៩.៣០ព្រឹក - ម៉ោង៥.៣០ល្ងាច<br>ថ្ងៃព្រហស្បតិ៍ ម៉ោង៩.៣០ព្រឹក - ម៉ោង៨យប់<br>ថ្ងៃសៅរ៍ ម៉ោង៩.៣០ព្រឹក - ម៉ោង១២.៣០ថ្ងៃត្រង់<br>ថ្ងៃអាទិត្យបិទទ្វារ | 8258 2788 | Hollywood Boulevard,<br>Salisbury Downs |
| បណ្ណាល័យ<br>Ingle Farm | ថ្ងៃច័ន្ទ - ថ្ងៃពុធ និង ថ្ងៃសុក្រ ម៉ោង៩.៣០ព្រឹក - ម៉ោង៥.៣០ល្ងាច<br>ថ្ងៃព្រហស្បតិ៍ ម៉ោង៩.៣០ព្រឹក - ម៉ោង៨យប់<br>ថ្ងៃសៅរ៍ ម៉ោង៩.៣០ព្រឹក - ម៉ោង៣.៣០រសៀល<br>ថ្ងៃអាទិត្យ ម៉ោង១.៣០រសៀល - ម៉ោង៤.៣០រសៀល | 8265 4717 | Beovich Road, Ingle Farm |

## ទីកន្លែងលេងកីឡា

**សកម្មភាពបន្តលេងកីឡា និងការកំសាន្ត គឺជាទ្រង់ទ្រាយសំខាន់នៃការរស់នៅរាល់ថ្ងៃក្នុងក្រុង Salisbury។ មជ្ឈមណ្ឌលកំសាន្តរបស់យើងបើកទ្វារធ្វើការ ៧ថ្ងៃក្នុងមួយអាទិត្យ ហើយផ្តល់ជូនកម្មវិធីផ្សេងៗជាច្រើនរៀបចំឡើងសម្រាប់ឲ្យលោកអ្នកបានសប្បាយ កំសាន្ត និងរៀនចេះនូវអ្វីៗដែលថ្មី។**

កម្មវិធីរបស់យើងមានរួមទាំងកីឡាបាល់បោះ(Basketball), កីឡាបោះបាល់ចូលកន្ត្រក(Netball), បោះប៊ូល, កីឡាបាល់ទាត់(Futsal), កីឡា Cricket, កីឡា Squash និង Racquetball, កីឡាវាយសី Racquetball, កីឡាកាយសម្ព័ន្ធ Gymnastics, កីឡាវាយប្រយុទ្ធ Martial Arts, កីឡារត់រំអិលដោយស្បែកជើងមានកង់(Rollerskating), កីឡាម្យ៉ាងសម្រាប់កូនក្មេងធ្វើចលនា Kindigym, កីឡាវាយពីងប៉ុង(Table Tennis), កីឡាបាល់ទះ (Volleyball), កីឡាហែលទឹក ហើយនិងកីឡាវាយតេនិស(Tennis)។

### ទីតាំងមជ្ឈមណ្ឌលលេងកំសាន្ត

| មជ្ឈមណ្ឌលលេងកំសាន្ត | ទូរស័ព្ទ | ទីកន្លែង |
|---|---|---|
| មជ្ឈមណ្ឌលលេងកំសាន្ត Parafield Gardens | 8281 4888 | Cnr Kings & Martins Road, Parafield Gardens |
| មជ្ឈមណ្ឌលលេងកំសាន្ត Ingle Farm | 8263 0411 | Corner Beovich Road & Roopena Street, Ingle Farm |
| មជ្ឈមណ្ឌលលេងកំសាន្ត Salisbury | 8258 1713 | Waterloo Corner Road, Salisbury North |

## ឧទ្យាន និងតំបន់បំរុងទុក

**ក្រុង Salisbury មានឧទ្យានដ៏ល្អស្អាត តំបន់បំរុងទុក តំបន់ទំនាបវាលភក់ល្បប់ និងទីធ្លាសម្រាប់ក្មេងលេងជាច្រើនសម្រាប់ពលរដ្ឋរស់នៅក្នុងតំបន់ និងអ្នកមកលេងដើម្បីរុករក និងសប្បាយរីករាយ។ ក្រុង Salisbury ពោរពេញដោយមោទនៈភាព ដោយមានឧទ្យាន និងតំបន់បំរុងទុកច្រើនជាង១៣០ និងផ្លូវលំសម្រាប់ដើរប្រវែងជាង៥០គ.ម។**

ផ្លូវលំសម្រាប់ដើរ និងជិះកង់ត្រូវបានបង្កើតឡើងនៅក្នុងតំបន់បម្រុងទុក និងតំបន់ទំនាបវាលភក់ល្បប់ មានរួមទាំង Little Para Trails, the Woodliparri Trail at Kaurna Park និង Dry Creek Linear Park ផងដែរ។ ឧទ្យានជាច្រើននៃឧទ្យានធំៗ និងតំបន់បម្រុងទុករបស់យើងមានទីធ្លាសម្រាប់ក្មេងលេងប្រកបដោយសុវត្ថិភាព កន្លែងដើរកំសាន្តពិចនិច និងចង្ក្រានអាំងសាច់ដោយឥតគិតថ្លៃ។

ចង់សម្រាប់ដាក់លាមកឆ្កែមានផ្តល់ជូននៅតាមឧទ្យាននីមួយៗ ហើយគឺជាការសំខាន់សម្រាប់ម្ចាស់ឆ្កែដែលត្រូវចងចាំថាគេត្រូវបានតម្រូវឲ្យបោសសំអាតលាមកឆ្កែរបស់គេ ពេលណានៅក្នុងបរិដ្ឋានសាធារណៈ។ ខាងក្រៅឧទ្យានដែលអនុញ្ញាតឲ្យមានឆ្កែ មានតំបន់បម្រុងទុក និងវាលស្មៅល្វឹងល្វើយជាច្រើនជាកន្លែងព្រលែងឆ្កែពីខ្សែចងក្នុងអំឡុងពេលម៉ោង៦.៣០យប់ និងម៉ោង៨ព្រឹក។ សូមចុច ត្រង់នេះ ដើម្បីរកមើលផែនទីឧទ្យាននៅក្បែរលោកអ្នកដែលទទួលរាក់ទាក់ឆ្កែ។

### ឧទ្យានសំខាន់ៗ

| ឈ្មោះឧទ្យាន | ទីតាំង |
|---|---|
| តំបន់បម្រុងទុក Harry Bowey Reserve | Riverside Drive, Salisbury Park |
| ឧទ្យាន Carisbrooke Park | Main North Road, Salisbury Park |
| ឧទ្យាន Pitman Park | Main entrance of Commercial Road, Salisbury |
| ឧទ្យាន Unity Park<br>ទីធ្លាសម្រាប់ក្មេងលេងដែលអាចចូលទៅដល់ដោយរទេះរុញកង់សម្រាប់កុមារពិការភាព | South Terrace, Pooraka |
| តំបន់ទំនាបវាលភក់ល្បប់ Watershed Wetlands<br>*កន្លែងលក់កាហ្វេ និងមជ្ឈមណ្ឌលកំសាន្ត Watershed* | Salisbury highway, Mawson Lakes |
| ទីធ្លាសម្រាប់កូនក្មេង St Kilda Playground និងផ្លូវលំសម្រាប់ដើរ Mangrove Trail<br>*ទីធ្លាសម្រាប់កូនក្មេងលេងបែបផ្សងព្រេងក្នុងតំបន់ និងការដើរមើលធម្មជាតិ* | Mangrove Street, St Kilda |
| តំបន់បម្រុងទុក Paddocks Reserve និងតំបន់ទំនាបវាលភក់ល្បប់ | Corner Bridge and Maxwell Roads, Para Hills |
| ឧទ្យាន Kaurna Park<br>*ការដើរមើលប្រវត្តិសាស្ត្រជនជាតិដើម Woodliparri* | Waterloo Corner Road, Burton |

## ការប្រមូលសំរាមនៅក្រុង Salisbury

**ក្រុង Salisbury ប្រមូលសំរាមចេញពីធុងសំរាមរបស់លោកអ្នកដោយឥតគិតថ្លៃ។ លោកអ្នកត្រូវដាក់សំរាមទាំងអស់នៅក្នុងធុងសំរាមមានកង់សម្រាប់ការប្រមូលយក។**

មានធុងសំរាមកង់បីប្រភេទខុសៗគ្នាដែលលោកអ្នកអាចប្រើ ហើយប្រភេទនីមួយៗគឺសម្រាប់ប្រភេទសំរាមខុសៗគ្នា:

1. ធុងសំរាមពណ៌បៃតងគម្របពណ៌លឿង សម្រាប់ដាក់វត្ថុយកទៅផលិតឡើងវិញមានរួមទាំងដបប្លាស្ទិក កំប៉ុង ក្រដាស ក្រឡកែវ ដបកែវ ក្រដាសរឹង និងប្រអប់ក្រដាសរឹង។ វត្ថុទាំងនេះអាចយកទៅផលិតឡើងវិញបាន មានន័យថាវត្ថុទាំងនេះត្រូវបានប្រមូលយក ដាក់តាមប្រភេទរបស់វា និងកិនកំទេចដើម្បីធ្វើជាវត្ថុដទៃទៀត។ សាលាក្រុងប្រមូលយកវត្ថុចេញពីធុងសំរាមនេះរៀងរាល់ពីរអាទិត្យម្តង។
2. ធុងសំរាមពណ៌បៃតងទំហំតូចគម្របពណ៌ក្រហម សម្រាប់ដាក់សំរាមធម្មតាក្នុងផ្ទះសម្បែង ហើយសាលាក្រុងប្រមូលយកសំរាមចេញពីធុងនេះរៀងរាល់មួយអាទិត្យម្តង។
3. ធុងសំរាមដាក់កាកសំណល់សួនច្បារសម្រាប់ដាក់បំណែកតូចៗក្នុងសួនច្បារ ស្មៅកាត់ និងស្លឹកឈើ ដែលលោកអ្នកអាចរកទិញបាន។ នេះគឺជាធុងសំរាមពណ៌បៃតងគម្របពណ៌បៃតង។ ធុងសំរាមនេះនឹងត្រូវសាលាក្រុងប្រមូលយកកាកសំណល់សួនច្បារចេញរៀងរាល់ពីរអាទិត្យម្តង ត្រូវចំអាទិត្យផ្ទុយគ្នានឹងធុងសំរាមដាក់វត្ថុយកទៅផលិតឡើងវិញគម្របពណ៌លឿង។ ធុងសំរាមនេះនឹងត្រូវសាលាក្រុងប្រមូលយកកាកសំណល់សួនច្បារចេញដោយឥតគិតថ្លៃ ក៏ប៉ុន្តែលោកអ្នកចាំបាច់ត្រូវចុះឈ្មោះក្នុងបញ្ជី។

### កំណត់សំគាល់សំខាន់

លោកអ្នកគួរដាក់ធុងសំរាមនៅលើជាយចិញ្ចើមថ្នល់ខាងក្រៅមុខផ្ទះរបស់លោកអ្នកមុនម៉ោង៧ព្រឹក នៅថ្ងៃដែលគេប្រមូលយកសំរាមទាំងនោះ។ ត្រូវដាក់ធុងសំរាមនៅលើជាយចិញ្ចើមថ្នល់ ដោយមានគម្របបើកចំហឆ្ពោះទៅផ្លូវថ្នល់ ឃ្លាតឆ្ងាយពីគ្នាក្នុងចម្ងាយតិចតួច - គួរបិទគម្របធុងសំរាម។

### ការប្រមូលយកសំរាមពិសេស: កាកសំណល់រឹង

ប្រសិនបើលោកអ្នកមានវត្ថុទាំងឡាយដូចជាគ្រឿងតុទូ ប្រដាប់ប្រើប្រាស់ គ្រឿងប្រដាប់អេឡិចត្រូនិចដែលលោកអ្នកលែងត្រូវការ ហើយចង់បោះចោលវា លោកអ្នកមានជម្រើសពីរសម្រាប់ការប្រមូលយកសំរាមរឹង:

1. ប្រព័ន្ធសំបុត្របញ្ជាក់ (Voucher System) ផ្តល់ជូនពលរដ្ឋរស់នៅក្នុងតំបន់នូវលទ្ធភាពប្រើប្រាស់ស្ថានីយផ្ទេរកាកសំណល់រឹងរបស់សាលាក្រុងដោយឥតគិតថ្លៃ ឬផ្ទុកកាកសំណល់រឹងមួយរ៉ឺមកសណ្តោងក្នុងមួយឆ្នាំ។
2. សម្រាប់ថ្លៃឈ្នួល១០ដុល្លា លោកអ្នកអាចរៀបចំបំរុងទុកបានរហូតដល់មួយខែជាមុន ដើម្បីឲ្យគេប្រមូលយកកាកសំណល់រឹងចេញពីផ្ទះរបស់លោកអ្នក។

សម្រាប់ព័ត៌មានអំពីសំរាមក្នុងផ្ទះសម្បែង វត្ថុយកទៅផលិតឡើងវិញ កាកសំណល់សួនច្បារ និងពេលម៉ោងប្រមូល សូមទូរស័ព្ទទៅអាជ្ញាធរផ្នែកគ្រប់គ្រងកាកសំណល់ខាងជើងទីក្រុងអាដីឡែត (NAWMA) តាម**លេខទូរស័ព្ទឥតគិតថ្លៃ** 1800 111 004។

## ការរស់នៅក្នុងក្រុង Salisbury

**មានកិច្ចការដទៃជាច្រើនទៀតដែលលោកអ្នកនឹងត្រូវការដឹងអំពី និងទូរស័ព្ទទៅដើម្បីធ្វើឲ្យជីវិតរស់នៅរបស់លោកអ្នកនៅទីនេះបានជាទីពេញលេញ និងអាចសប្បាយរីករាយ ហេតុដូច្នេះយើងមានផ្តល់ព័ត៌មានសម្រាប់ការទាក់ទងសំខាន់ៗមួយចំនួន ដើម្បីជួយក្នុងការស្រាវជ្រាវរបស់លោកអ្នក។ លោកអ្នកក៏អាចទាញយក** community directory **(បញ្ជីសហគមន៍) ផងដែរ។**

### សាលារៀន និងកន្លែងថែទាំកូនក្មេង

មានសាលារដ្ឋ និងឯកជនចំនួន៤៤ និងមណ្ឌលថែទាំកូនក្មេងចំនួន៣០ នៅក្នុងក្រុង Salisbury ដែលផ្តល់ជូនជម្រើសអប់រំផ្នែកសាសនា និងការអប់រំដែលមិនទាក់ទងនឹងសាសនា។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងក្រសួងអប់រំ និងសេវារបស់កូនក្មេង។ លេខទូរស័ព្ទឥតគិតថ្លៃ: 1800 088 158 ឬបើកមើលវិបសាយ www.decs.sa.gov.au

## យានជំនិះសាធារណៈ

ក្រុង Salisbury មានសេវាផ្តល់យ៉ាងល្អដោយយានជំនិះសាធារណៈ ដោយមានការតភ្ជាប់ទាំងរថយន្តក្រុង និងទាំងរថភ្លើងទៅទីក្រុងអាដឺឡែត និងមជ្ឈមណ្ឌលដទៃទៀតក្នុងតំបន់។ សម្រាប់តារាងពេលវេលា និងព័ត៌មានដទៃទៀត សូមទាក់ទងទូរស័ព្ទផ្តល់ព័ត៌មានសម្រាប់តំបន់ខាងក្នុង និងជាយក្រុងអាដឺឡែត លេខ 8210 1000 ឬបើកមើលវិបសាយ www.adelaidemetro.com.au

## កម្មវិធីយុវជន

ក្រុង Salisbury មានកម្មវិធីមួយចំនួនដើម្បីផ្គត់ផ្គង់មនុស្សវ័យក្មេងអាយុ១២ ទៅ២៥ឆ្នាំ និងគ្រួសាររបស់គេ។ មានភ្នាក់ងារ និងសេវាយុវជនមួយចំនួនចាត់ចែងក្រៅសាលាក្រុង។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងសេវាផ្តល់ព័ត៌មានសហគមន៍ Salisbury តាមទូរស័ព្ទលេខ 8406 8533។

## សេវាសម្រាប់មនុស្សចាស់វិជ្ជមាន

សេវាសម្រាប់មនុស្សចាស់វិជ្ជមាន ផ្គត់ផ្គង់មជ្ឈមណ្ឌលសហគមន៍សម្រាប់មនុស្សអាយុច្រើនជាង៥០ឆ្នាំ ដើម្បីជួបជុំគ្នា ចូលរួមក្នុងសកម្មភាពទាំងឡាយ និងស្វែងរកការផ្គត់ផ្គង់សម្រាប់បញ្ហាណាមួយដែលគេអាចជួបប្រទះ។ សេវាទាំងនេះតាំងនៅមជ្ឈមណ្ឌល Jack Young ទូរស័ព្ទលេខ 8258 7286 និងមជ្ឈមណ្ឌល Para Hills ទូរស័ព្ទលេខ 8395 1520។

## សេវាសុខភាព

មានមន្ទីរពេទ្យសាធារណៈពីរក្នុងតំបន់ខាងជើង គឺមន្ទីរពេទ្យ Lyell McEwin និងមន្ទីរពេទ្យ Modbury ព្រមទាំងមន្ទីរពេទ្យ Royal Adelaide និងមន្ទីរពេទ្យ Women's and Children's ផងដែរ។ មជ្ឈមណ្ឌលថែទាំសុខភាពជាបឋមរបស់ក្រុង Salisbury តាំងនៅ Hollywood Boulevard, Salisbury Downs ទូរស័ព្ទលេខ 8281 7644។

## សេវាស្វែងរកការងារធ្វើ និងការហ្វឹកហ្វឺន

សេវាស្វែងរកការងារធ្វើ និងការហ្វឹកហ្វឺនបង្ហាញឲ្យឃើញយ៉ាងល្អនៅក្រុង Salisbury។ ជាពិសេសសាលាក្រុងធ្វើប្រតិបត្តិការស្វែងរកការងារសម្រាប់សហគមន៍ សេវាសម្រាប់ការហ្វឹកហ្វឺន និងស្ម័គ្រចិត្ត តាមរយៈមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្លាំងពលកម្ម និងអាជីព ដែលតាំងនៅ John Street, Salisbury ទូរស័ព្ទលេខ 1800 619 933។

## ការចូលសញ្ជាតិ

ដើម្បីក្លាយជាពលរដ្ឋអូស្ត្រាលី លោកអ្នកអាចយកពាក្យសុំពីក្រសួងអន្តោប្រវេសន៍ ទូរស័ព្ទលេខ 13 18 80។ ការប្រារព្ធពិធីចូលសញ្ជាតិនៅក្រុង Salisbury ត្រូវបានប្រព្រឹត្តទៅតាមពេលម៉ោងពេញទូទាំងឆ្នាំ។ ដើម្បីស្វែងយល់ច្រើនថែមទៀត សូមទាក់ទងសាលាក្រុងតាមទូរស័ព្ទលេខ 8406 8222។

## ទីកន្លែងថ្វាយបង្គំព្រះ

ក្រុង Salisbury គឺជាសហគមន៍វប្បធម៌ចម្រុះដែលមានតំណាងសាសនា និងនិកាយជាច្រើន។ សម្រាប់ព័ត៌មានបន្ថែមអំពីសេវាណាមួយ សូមយោងទៅសៀវភៅព័ត៌មានសហគមន៍ ឬទូរស័ព្ទទៅសេវាផ្តល់ព័ត៌មានសហគមន៍ Salisbury លេខ 8406 8533។

## ការស្ម័គ្រចិត្ត

ការស្ម័គ្រចិត្ត អាចជាមធ្យោបាយដ៏ល្អដើម្បីបង្កើតមិត្តភក្តិ និងតភ្ជាប់ជាមួយសហគមន៍ក្នុងតំបន់របស់លោកអ្នក ព្រមទាំងដើម្បីពង្រីកមុខជំនាញថ្មីៗ និងបង្កើតជំនឿទុកចិត្តរបស់លោកអ្នកផងដែរ។ ក្រុង Salisbury សម្របសម្រួលកម្មវិធីស្ម័គ្រចិត្ត តភ្ជាប់មនុស្សក្នុងតំបន់ជាមួយឱកាសផ្សេងៗគ្នាមួយចំនួន ចាប់ពីការធ្វើកិច្ចការក្នុងចង្ក្រាន ទៅដល់ការនាំផ្លូវដើរលេងមើលតំបន់ទំនាបវាលភក់ល្បប់នៅក្រុង Salisbury និងអ្វីៗទាំងឡាយទៀត។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអ្នកសម្របសម្រួលផ្នែកសេវាស្ម័គ្រចិត្ត តាមទូរស័ព្ទលេខ 8406 8475។

CITY OF
Salisbury

City of Salisbury
12 James Street
Salisbury SA 5108
T: 8406 8222
F: 8281 5466
www.salisbury.sa.gov.au